# លទ្ធិប្រជាធិបតេយ្យ ចុះថយ ?

ក្រោយពីការរលំ នៃរបងទីក្រុង ប៉ែកឡាំង នៅឆ្នាំ ១៩៨៩, គេឃើញថា កម្លាំងនៃលទ្ធិប្រជាធិបតេយ្យ មានការរីកចំរើនរហ័ស នៅក្នុងបណ្តាលប្រទេសខាងកើត នៃទ្វីបអឺរ៉ុប។ វាគឺជាទីបញ្ចប់ នៃប្រវត្តិសាស្ត្រ ដែលលោក Francis Fukuyama បានសរសេរ អំពីជ័យជំនះ នៃលោកសេរី លើលោកកុម្មុយនិស្ត។ តែបន្ទាប់ក្រោយមក វាមានកើត នូវគំនិតជាតិនិយមជ្រុលនៅលើពិភពលោក និង ចលនាសាសនានិយម នៅក្នុងបណ្តាលប្រទេសអ៊ីស្លាម ដែលនាំអោយពិភពលោក ធ្លាក់ទៅក្នុងអសន្តិសុខមិនទៀង សូម្បីតែ សហរដ្ឋអាមេរិច ដែលជាមហានគរប្រជាធិបតេយ្យ ក៏ជួបប្រទះ នូវបាតុភូតនេះដែរ។ ស្ថានភាពនេះឯង ជាលាភជ័យ សម្រាប់ជនផ្តាច់ការទាំងឡាយ នៅក្នុងប្រទេសមួយចំនួន ដំឡើងបាន នូវរបបសមស្ត ក្នុងនាមសន្តិភាពមិនពិត។ មួយវិញទៀត នយោបាយ នៃលោក ត្រុម អង្កែលខ្ចង លោក ពូទិន និង គិម ជុង អ៊ុន វាហាក់បីដូចមានភាពធូរ ចំពោះជនផ្តាច់ការ ដែលនាំអោយ សហរដ្ឋអាមេរិច មានអោនភាព ជាមហាអំណាច ការពារ សេរីភាព និង លទ្ធិប្រជាធិបតេយ្យ។ ដូច្នេះ អំណាចផ្តាច់ការ វាទៅជា ភាពជម្នះ ព្រោះមានថែមទៀត មហាចិន និង ប្រទេសរុស្ស៊ី ជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខ នៃ អ.ស.ប. ជាអ្នកការពារ នៅចំពោះមុខអនានុភាព នៃលោកសេរី។ តើវាជាការផ្តើមឡើងវិញ នៃប្រវត្តិសាស្ត្រ របស់លោក Francis Fukuyama ដែរឬទេ ?

**ឧប សៅ សង្ហា** **គំនិត** **២២ មិថុនា ២០១៨**